**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ៣៤៣ ទស.សណ.អទច

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពីការចុះឈ្មោះរៀបចំទទួលភ្ញៀវទេសចរចិន

## តាមប្រព័ន្ធវាយតម្លៃបញ្ជាក់កម្រិតសេវាកម្មទេសចរណ៍សម្រាប់ទីផ្សារទេសចរចិន

យោងអនុស្សរណៈយោគយល់គ្នា នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០០ រវាងក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធររដ្ឋបាលទេសចរណ៍ជាតិនៃសាធារណរដ្ឋប្រជាមានិតចិនស្តីអំពីផែនការអនុវត្តន៍សម្រាប់ការធ្វើដំណើរក្រៅប្រទេសរបស់ប្រជាពលរដ្ឋចិនមកកាន់ព្រះរាជាណាចក្រកម្ពុជា និងយុទ្ធសាស្ត្រទាក់ទាញទេសចរចិន និងសៀវភៅសអំពី "China Ready" សម្រាប់ទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍បានរៀបចំបង្កើតមជ្ឈមណ្ឌលទ្រទ្រង់ "China Ready" សម្រាប់ទេសចរណ៍កម្ពុជាដើម្បីចាត់ចែងអនុវត្តន៍សៀវភៅស "China Ready" សម្រាប់ទេសចរណ៍កម្ពុជា។

កន្លងមកក្រសួងទេសចរណ៍បានទទួលស្គាល់ការីទេសចរណ៍ចំនួន៤៥ ក្រុមហ៊ុនដែលបានចុះឈ្មោះក្នុងបញ្ជីរៀបចំទទួលភ្ញៀវទេសចរចិន ដើម្បីចូលរួមចំណែកក្នុងការទាក់ទាញ និងទទួលស្វាគមន៍ទេសចរចិនឲ្យសម្រេចបានតាមគោលដៅប្រមាណ ២ លាន នាក់ នាឆ្នាំ២០២០។ ក្រសួងទេសចរណ៍សូមណែនាំដល់ការីទេសចរណ៍ ដែលមានឈ្មោះក្នុងបញ្ជីរៀបចំទទួលភ្ញៀវទេសចរចិនចំនួន ៤៥ ក្រុមហ៊ុន និងការីទេសចរណ៍មានទីផ្សារទេសចរណ៍ចិនមកដាក់ពាក្យស្នើសុំការវាយតម្លៃបញ្ជាក់កម្រិតសេវាកម្មទេសចរណ៍សម្រាប់ទីផ្សារទេសចរណ៍ចិន (Cambodia China Ready Accreditation) ប្រតិបត្តិករទេសចរណ៍ចាំបាច់ត្រូវមាន៖

១. ពាក្យស្នើសុំវាយតម្លៃបញ្ជាក់កម្រិតសេវាកម្មសម្រាប់ទីផ្សារទេសចរចិន។
២. កិច្ចសន្យាគោរពលក្ខខណ្ឌវាយតម្លៃ។
៣. អាជ្ញាបណ្ណទេសចរណ៍ដែលមានសុពលភាព។
៤. បង្កាន់ដៃបង់ប្រាក់ពាក្យស្នើសុំ។

ទទួលបានសេចក្តីជូនដំណឹងខាងលើនេះ សូមលោក លោកស្រី ការីទេសចរណ៍ទាំងអស់ដែលកំពុងប្រកបអាជីវកម្មទេសចរណ៍ជាការីទេសចរណ៍ទទួលភ្ញៀវទេសចរចិន ត្រូវរៀបចំឯកសារពាក់ព័ន្ធទាំងឡាយតាមខ្លឹមសារនៃសេចក្តីណែនាំនេះដើម្បីមកដាក់ពាក្យស្នើសុំនៅក្រសួងទេសចរណ៍ (មជ្ឈមណ្ឌលទ្រទ្រង់ "China Ready" សម្រាប់ទេសចរណ៍កម្ពុជា) ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

**បញ្ជាក់៖** ប្រតិបត្តិករអាចយកពាក្យស្នើសុំតាមរយៈគេហទំព័រ៖www.cambodia-chinaready.com ឬទំនាក់ទំនងផ្ទាល់មកទូរស័ព្ទលេខ៖ ០៨៩ ៧៦៧ ៦៦៤

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន**

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងមហាផ្ទៃ
-មន្ទីរទេសចរណ៍រាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
-សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
-សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
-ការីទេសចរណ៍មានទីផ្សារទេសចរណ៍ចិន
"ដើម្បីអនុវត្តន៍"
-ឯកសារ-កាលប្បវត្តិ